# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់នៅតាខ្មៅ
# ថ្ងៃទី០៤ ឧសភា ២០១៧

អត្ថបទទី១៖ កក ៨,២៦-៤០
ដំណឹងល្អ៖ យហ ៦,៤៤-៥១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងស្តាប់អត្ថបទដែលនិយាយអំពី លោកភីលីពនិងមន្ត្រីម្នាក់ដែលមិនមែនជាគ្រីស្តបរិស័ទប៉ុន្តែគាត់កំពុងអានគម្ពីរ។ ពេលនោះមានលោកភីលីព ដែលជាគ្រីស្តទូត ជាសាវ័ករបស់ព្រះយេស៊ូ បានសួរមន្ត្រីម្នាក់នោះថាយល់ឬមិនយល់? គាត់ឆ្លើយថាគាត់មិនសូវយល់ព្រោះគ្មាននរណាដែលបំភ្លឺខ្ញុំសោះ ហេតុនេះហើយលោកភីលីពនិយាយថា ឥលូវនេះយើងធ្វើដំណើរជាមួយគ្នាខ្ញុំនឹងពន្យល់។ ក្រោយមកមន្ត្រីនោះគាត់ចាប់ផ្តើមភ្លឺ គាត់សប្បាយចិត្តពេលគាត់ស្តាប់ជីវិតរបស់ព្រះយេស៊ូ ដោយគាត់យល់ថាព្រះយេស៊ូយាងមកដើម្បីឲ្យជីវិតរបស់គាត់ទៅជាជីវិតដែលមានកម្លាំងថែមទៀត មានសេចក្តីសុខសាន្តថែមទៀត។ ពេលគាត់ឃើញកន្លែងដែលមានស្រះទឹកមួយ គាត់សុំលោកភីលីពដើម្បីធ្វើពិធីជ្រមុជទឹក រំពេចនោះគាត់បានទៅប្រកាសអំពីអំណរសប្បាយដែលគាត់បានទទួល។ ដូចគ្នានៅទីនេះយើងមានទាំងលោកភីលីពគឺបងប្អូនដែលទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយ និងមន្ត្រីគឺបងប្អូនទាំងអស់ដែលមិនទាន់ទទួលអគ្គសញ្ញាជ្រមុជទឹក។ ឲ្យភីលីពពន្យល់មន្ត្រីអំពីព្រះបន្ទូលថ្ងៃនេះ **ខ្ញុំជាអាហារដែលផ្តល់ជីវិត** ជាអត្ថបទដែលភីលីពត្រូវគិតអំពីតួនាទីរបស់យើងអំពីបេសកកម្មដែលយើងបានទទួល យើងធ្វើដូចម្តេចដើម្បីណែនាំឲ្យយុវជនដែលនៅទីនេះមានលោកតា លោកយាយ លោកពូ អ្នកមីង យល់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់បំភ្លឺជីវិតរបស់យើងយ៉ាងដូចម្តេច។ ថ្ងៃនេះយើងត្រូវការពន្យល់ដល់បងប្អូនទាំងអស់ថា ព្រះយេស៊ូជាអាហារដែលផ្តល់ជីវិតអស់កល្បជានិច្ច ព្រះយេស៊ូយាងមកដើម្បីឲ្យយើងមានជីវិតដ៏បរិបូរណ៍មានន័យដូចម្តេច? សម្រាប់បងប្អូនជាមន្ត្រីមានន័យថាអ្នកដែលកំពុងរិះគិតអំពីព្រះបន្ទូលខ្ញុំសង្ឃឹមយើងអាចជួបភីលីពដើម្បីបំភ្លឺ ដែលមានលោកបូជាចារ្យ គ្រូអប់រំជំនឿ។ យើងធ្វើដូចម្តេចដើម្បីជួបអ្នកដែលបំភ្លឺជីវិតយើង ដើម្បីទទួលសេចក្តីសុខ ដូចមន្ត្រីម្នាក់នោះពេលគាត់ទទួលជីវិតថ្មីគាត់សប្បាយចិត្តណាស់ ដោយសារគាត់បានជួបជាមួយព្រះយេស៊ូហើយ។ យប់នេះយើងអធិដ្ឋានរបៀបពិសេស ដើម្បីគិត**តើព្រះយេស៊ូចង់ឲ្យខ្ញុំធ្វើអ្វីខ្លះ**

**នៅក្នុងជីវិតខ្ញុំ? តើព្រះយេស៊ូចង់ឲ្យខ្ញុំធ្វើអ្វីខ្លះដើម្បីជួយអ្នកដទៃ? តើព្រះយេស៊ូចង់ឲ្យខ្ញុំធ្វើអ្វីខ្លះដើម្បីជួយសាលាខ្ញុំ ជួយភូមិខ្ញុំ ជួយសង្គមខ្ញុំ ជួយពិភពលោកខ្ញុំ?** ពេលយើងចែកជាក្រុមដើម្បីអធិដ្ឋានពេលនោះយើងរិះគិតសំនួរនេះ។ ខ្ញុំស្គាល់ព្រះយេស៊ូហើយ ខ្ញុំកំពុងធ្វើដំណើរជាមួយព្រះយេស៊ូ តើព្រះអង្គចង់ឲ្យខ្ញុំធ្វើអ្វីខ្លះដើម្បីជួយបងប្អូនឯទៀតៗ? ព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យយើងមានជីវិត ព្រះយេស៊ូយាងមកដើម្បីចិញ្ចឹមជីវិតរបស់យើង។ ព្រះយេស៊ូយាងមកខ្ញុំចង់ឲ្យមានសេចក្ដីសុខសាន្ត ចង់មានការងារធ្វើ ឲ្យមនុស្សលោកចេះស្រឡាញ់គ្នាទៅវិញទៅមក នេះជារបៀបព្រះយេស៊ូទន្ទឹងរងចាំឲ្យយើងជួយព្រះអង្គលើផែនដីនេះ។ ព្រះយេស៊ូទន្ទឹងរងចាំ ឲ្យបងប្អូនទាំងអស់ដែលយើងជួបរកឃើញម្ហូបអាហារសម្រាប់ជីវិតគឺ គឺឲ្យគេយល់ថាគេឆ្អែតដោយសារគេបរិភោគច្រើន តែធ្វើយ៉ាងមិចដើម្បីឲ្យជីវិតខ្ញុំមានសេចក្ដីសុខ ធ្វើយ៉ាងមិចដើម្បីឲ្យជីវិតខ្ញុំមានអំណរសប្បាយ។ ពេលយើងបានទៅសាលាយើងសប្បាយចិត្ត ពេលយើងមានការងារធ្វើយើងសប្បាយចិត្ត ពេលយើងអាចកសាងគ្រួសារមួយប្រកបដោយសុភមង្គលយើងសប្បាយចិត្ត។ អំណរសប្បាយដែលព្រះយេស៊ូចង់ឲ្យយើងមាន គឺធ្វើយ៉ាងណាដើម្បីបង្កើតទំនាក់ទំនងរវាងគ្នានឹងគ្នា ដូចជាមហាគ្រួសារមួយ។ យប់នេះយើងមកពីគ្រប់ទីកន្លែង ដែលបង្ហាញថាយើងជាគ្រួសារមួយដែលកំពុងកសាងព្រះសហគមន៍ កសាងសង្គមដែលប្រកបដោយសេចក្ដីសុខសាន្ត។ យើងមាននិស្សិតទេវវិទ្យាល័យ ដែលយប់នេះប្រហែលសប្បាយចិត្ត និងមានកម្លាំងថែមទៀតដើម្បីស្រឡាញ់ព្រះយេស៊ូថែមទៀត ដោយសុខចិត្តលះបង់អ្វីៗទាំងអស់ ដើម្បីបម្រើព្រះយេស៊ូយេស៊ូ បម្រើព្រះសហគមន៍ បម្រើបងប្អូនទាំងអស់ ដោយធ្វើជាបូជាចារ្យនៅថ្ងៃអានាគត។ យើងមានប្អូនជាច្រើនដែលកំពុងស្ដាប់ព្រះបន្ទូល ហើយបន្តអប់រំគ្នាឲ្យចេះស្រឡាញ់ដូចព្រះយេស៊ូ។

ថ្ងៃនេះយើងបន្តអធិដ្ឋាន ដោយដឹងថាយើងមានក្រុមភីលីព ដែលពន្យល់ព្រះគម្ពីរដល់ក្រុមមន្ត្រី។ ព្រះយេស៊ូចាប់ដៃខ្ញុំ ព្រះយេស៊ូធ្វើដំណើរជាមួយខ្ញុំ ថ្ងៃនេះយើងត្រូវគិត **តើព្រះយេស៊ូចិញ្ចឹមខ្ញុំរបៀបណា?** យើងមានកិច្ចការច្រើនណាស់ដែលព្រះយេស៊ូត្រូវឲ្យយើងធ្វើ។ យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គបំភ្លឺយើងថែមទៀតដើម្បីឲ្យជីវិតយើងតស៊ូថែមទៀត ដោយដឹងថាការតស៊ូរបស់យើង ណែនាំឲ្យយើងរកឃើញសេចក្ដីសុខយ៉ាងពិតប្រាកដ។ អាម៉ែន។